00922758

E288/1/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 21 / 06 / 2013
ម៉ោង (Time/Heure): 10:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣

**ជូនចំពោះ៖** ភាគីនៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក /លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និង សវនាការផ្សេងៗនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និងសំណើ E288/1

១. អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់នាពេលថ្មីៗនេះថា សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ នៅក្នុងសំណុំរឿង ០០២/០១ នឹងប្រព្រឹត្តទៅដើម្បីអនុញ្ញាតឲ្យភាគីបង្ហាញឯកសារសំខាន់ៗ ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម និងតួនាទីរបស់ជនជាប់ចោទ (ឯកសារ E288)។ សវនាការដេញដោលលើឯកសារនេះនឹងប្រព្រឹត្តទៅនៅពេលបញ្ចប់ការផ្តល់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-801 ដែលសក្ខីកម្មរបស់គាត់ត្រូវបានគ្រោងចាប់ផ្តើមនៅថ្ងៃ ពុធ ទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣។ សក្ខីកម្មនេះរំពឹងថានឹងត្រូវការពេលវេលាចំនួន ១ ថ្ងៃ។ ហេតុដូច្នេះ សវនាការដេញដោលលើឯកសារនេះ អាចចាប់ផ្តើមពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ និងទំនងជាមិនចាប់ផ្តើមនៅសប្តាហ៍ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ នោះឡើយ។

២. សហព្រះរាជអាជ្ញាបានស្នើសុំពេលវេលាចំនួន ៣ ថ្ងៃដើម្បីបង្ហាញឯកសារសំខាន់ៗនៅក្នុងសវនាការនេះ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជាដំបូងក៏បានស្នើសុំរយៈពេលដូចគ្នានេះដែរ ប៉ុន្តែបានកាត់បន្ថយរយៈពេលមកនៅត្រឹមមួយថ្ងៃកន្លះវិញនៅក្នុងកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ

២០១៣។ មេធាវីការពារក្ដី នួន ជា បានគូសបញ្ជាក់ថា ពួកគាត់ពុំមានបំណងបង្ហាញឯកសារសំខាន់ៗនៅសវនាការនេះទេ ប៉ុន្តែបានស្នើសុំពេលវេលាអតិបរមាចំនួន ០១ ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងការបង្ហាញឯកសាររបស់ភាគីដទៃទៀត។

៣. នៅក្នុងសំណើ E263 មេធាវីការពារក្ដី ខៀវ សំផន លើកឡើងថា សវនាការដេញដោលលើឯកសារសំខាន់ៗនេះ រំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងដោយតទល់គ្នា ល្គឹកណាសវនាការទាំងនោះពុំមានចេតនាអនុញ្ញាតឱ្យមានការលើកទឡ្ហីករណ៍តទល់ ទាក់ទងនឹងឯកសារដែលត្រូវបានបង្ហាញ និងដោយសារភាពមិនស៊ីសង្វាក់គ្នាដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការធ្វើសវនាការដេញដោលលើឯកសារនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (កថាខណ្ឌ ៤-១២)។ ពួកគាត់លើកឡើងថា មេធាវីការពារក្ដី ខៀវ សំផន ត្រូវតែទទួលបានឱកាសពិតប្រាកដដើម្បីពិភាក្សាអំពីការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងជនជាប់ចោទ ហើយសវនាការបន្ថែមស្ដីពីភាពអាចទទួលយកបានលើឯកសារ គួរគប្បីត្រូវបានកំណត់កាលបរិច្ឆេទ។ មេធាវីការពារក្ដី ខៀវ សំផន ក៏បានលើកឡើងទៀតថា ឯកសារសំខាន់ៗដែលត្រូវបានលើកបង្ហាញមកដល់ពេលបច្ចុប្បន្ន គួរត្រូវបានពិនិត្យរកតម្លៃជាភស្តុតាងបន្ថែមទៀត ដើម្បីអនុញ្ញាតឱ្យមានការពិភាក្សាដេញដោលតទល់ពេញលេញ ហើយគួរផ្ដល់ឱកាសនៅចុងបញ្ចប់កិច្ចដំណើរការនីតិវិធីដើម្បីវាយតម្លៃល្អិតល្អន់អំពីសំណុំភស្តុតាងទាំងមូលប្រឆាំងនឹងជនជាប់ចោទ (កថាខណ្ឌ ៤៦, ៥២ និង ៥៥)។

៤. អង្គជំនុំជម្រះធ្លាប់បានពន្យល់ថា សវនាការដេញដោលលើឯកសារសំខាន់ៗ ដែលត្រូវបានធ្វើនៅពេលបញ្ចប់សវនាការមួយវគ្គៗ គឺជាការចាំបាច់ ដោយហេតុថា ពុំមានភាពចាំបាច់នៅក្នុងក្របខណ្ឌគតិយុត្តនៅ អ.វ.ត.ក ដើម្បីដាក់ឯកសារតែតាមរយៈសាក្សី ឬអ្នកជំនាញនោះឡើយ។ ហេតុដូច្នេះ សវនាការលើឯកសារទាំងនេះត្រូវបានរៀបចំឡើងដើម្បីអនុញ្ញាតឱ្យភាគីគូសបញ្ជាក់អំពីឯកសារទាំងឡាយ ដែលភាគីបានជឿថាពាក់ព័ន្ធទៅនឹងចំណុចអង្គហេតុនៃសវនាការនីមួយៗ សម្រាប់ជាប្រយោជន៍ដល់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះធ្លាប់បានគូសបញ្ជាក់ថា គោលបំណងនៃសវនាការទាំងនេះ គឺដើម្បីធានាថា ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ត្រូវបានលើកឡើងយ៉ាងសមស្របនៅចំពោះមុខអង្គជំនុំជម្រះ។ សវនាការទាំងនេះក៏ដើម្បីអនុញ្ញាតឱ្យសាធារណជនអាចពិនិត្យមើលឯកសារសវនាការ ដោយពិនិត្យទៅលើទំហំដ៏ធំលើទិដ្ឋភាពផ្នែកឯកសារនៃសំណុំរឿង០០២ ហើយដោយសាធារណជនទូទៅអាចពុំបានដឹងអំពីខ្លឹមសារនៃឯកសារទាំងនេះ (ឯកសារ E201/2)។

៥. ដោយហេតុថា សវនាការដាច់ដោយឡែកត្រូវបានធ្វើជាក់លាក់ ដើម្បីផ្ដល់ឱកាសឱ្យមានការជំទាស់លើភាពអាចទទួលយកបាននៃឯកសារទាំងអស់ដែលត្រូវបានដាក់នៅក្នុងសវនាការរួចមកហើយ ដូច្នេះការលើកទឡ្ហីករណ៍ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឯកសារ ពុំត្រូវបានអនុញ្ញាតឡើយក្នុងអំឡុងសវនាការទាំងនេះ។ យ៉ាងណាក៏ដោយ ជនជាប់ចោទ ឬមេធាវីការពារក្ដី ពុំត្រូវបានហាមឃាត់មិនឱ្យពិភាក្សាអំពីភាពពាក់ព័ន្ធ ឬតម្លៃជា

ភស្តុតាងនៃឯកសារដែលត្រូវបង្ហាញក្នុងអំឡុងពេលសវនាការទាំងនោះឡើយ។ យោងតាមការចោទប្រកាន់របស់មេធាវីការពារក្តី ខៀវ សំផន ដែលថា ក្រុមខ្លួនមិនមានឱកាសគ្រប់គ្រាន់សម្រាប់ការលើកទឡ្ហីករណ៍តទល់ទាក់ទងនឹងឯកសារទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យមេធាវីការពារក្តី ខៀវ សំផន គូសបញ្ជាក់នៅកិច្ចប្រជុំរៀបចំសវនាការអំពីពេលវេលាដែលក្រុមខ្លួនត្រូវការសម្រាប់គោលបំណងនេះ និងសូមបញ្ជាក់អំពីឯកសារដែលពួកគាត់មានបំណងជំទាស់ ឬធ្វើអត្ថាធិប្បាយបន្ថែម។ ក្រោយពេលទទួលការគូសបញ្ជាក់ទាំងនេះ អង្គជំនុំជម្រះនឹងចេញកាលបរិច្ឆេទនៃការពិភាក្សាដេញដោលលើឯកសារជាលើកចុងក្រោយ នៅក្នុងសំណុំរឿង ០០២/០១ (ឧបសម្ព័ន្ធ IV(ខ)៖ បញ្ជីនៃសំណើនានាដែលកំពុងត្រូវបានពិចារណានៅចំពោះមុខអង្គជំនុំជម្រះ ដែលនៅក្នុងនោះ នៅពុំទាន់មានសេចក្តីសម្រេច (ដែលត្រូវផ្តល់ទៅភាគីពីសំណាក់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣) ទំព័រ ២៥ ជាភាសាអង់គ្លេស)។

៦. នៅឯកិច្ចប្រជុំរៀបចំសវនាការ មេធាវីការពារក្តី ខៀវ សំផន បានបដិសេធទទួលយកទាំងឱកាសនៃបង្ហាញអំពីឯកសារសំខាន់ៗសម្រាប់សវនាការនាពេលខាងមុខនេះ និងទាំងឱកាសធ្វើអត្ថាធិប្បាយអំពីឯកសារសំខាន់ៗដែលភាគីផ្សេងៗទៀតបានបង្ហាញ ឬក៏មិនបានគូសបញ្ជាក់អំពីថិរវេលាបន្ថែមដែលពួកគេបានស្នើសុំ ដើម្បីសួរដេញដោល ឬផ្តល់យោបល់តាមវិធីផ្សេងទៀតទៅលើឯកសារនានាដែលត្រូវបានបង្ហាញនាពេលកន្លងមកនៅចំពោះមុខអង្គជំនុំជម្រះទេ។ នៅក្នុងចម្លើយតបដោយផ្ទាល់មាត់ចំពោះឯកសារ E263 នៅឯកិច្ចប្រជុំរៀបចំសវនាការ សហព្រះរាជអាជ្ញាបានលើកឡើងថា សវនាការដេញដោលលើឯកសារសំខាន់ៗ ដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេលសវនាការ មានលក្ខណៈចុះសម្រុងទាំងស្រុងទៅនឹងសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានសវនាការប្រកបដោយយុត្តិធម៌ និងមានការតទល់ ហើយសវនាការនេះគឺដើម្បីពង្រឹងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី។ វិធីសាស្ត្រទូទៅរបស់អង្គជំនុំជម្រះចំពោះឯកសារនានានៅឯសវនាការ បានផ្តល់នូវឱកាសគ្រប់គ្រាន់ដល់ភាគីនានា ក្នុងការជំទាស់ទៅនឹងភាពទទួលយកបាននៃភស្តុតាងដែលបានស្នើនៅក្នុងសវនាការ ដើម្បីលើកឡើងនូវចំណុចសំខាន់ៗនៃកំណត់ហេតុជាឯកសារពីទស្សនៈរបស់ភាគីនោះ ឬដើម្បីធ្វើការសង្កេតតាមវិធីផ្សេងៗទៀត ទៅលើភាពពាក់ព័ន្ធ និងតម្លៃជាភស្តុតាងនៃឯកសារនានាដែលភាគីផ្សេងៗទៀតបានដាក់។ ទោះបី មេធាវីការពារក្តី ខៀវ សំផន បានអះអាងជាញឹកញយនៅក្នុងសវនាការថា ក្រុមខ្លួនពុំមានឱកាសក្នុងការពិភាក្សាដេញដោលឱ្យបានពេញលេញពាក់ព័ន្ធនឹងឯកសារនានាក៏ដោយ ក៏ពួកគេជាញឹកញាប់មិនបានប្រើប្រាស់ឱកាសឱ្យធ្វើដូច្នេះនៅពេលត្រូវបានផ្តល់ឱ្យជាច្រើនដោយអង្គជំនុំជម្រះនោះឡើយ។ ទោះបីវាជាសិទ្ធិរបស់ពួកគេក៏ដោយ តែគេមិនគួរសន្និដ្ឋានថា អង្គជំនុំជម្រះមិនបានផ្តល់ឱកាសគ្រប់គ្រាន់ឱ្យពួកគេធ្វើការពិភាក្សាដេញដោលពាក់ព័ន្ធនឹងឯកសារ ក្នុងអំឡុងពេលសវនាការក្នុងសំណុំរឿង ០០២/០១ នោះទេ។ ថ្វីត្បិតតែយ៉ាងនេះក្តី សហព្រះរាជអាជ្ញាបានលើកឡើងថា ឱកាសចុងក្រោយមួយគួរត្រូវផ្តល់ឱ្យមេធាវីការពារក្តី ខៀវ សំផន នៅក្នុងសវនាការដេញដោលលើឯកសារសំខាន់ៗនាពេលខាងមុខ ដើម្បីដាក់នូវសេចក្តីសន្និដ្ឋានបន្ថែម ពាក់ព័ន្ធនឹងឯកសារនានាដែលពួកគេយល់ថាមានមូលដ្ឋាន

ពេញលេញ និងបានផ្តល់យោបល់ថា រយៈពេល ២ ម៉ោងគប្បីត្រូវផ្តល់ឲ្យក្រុមមេធាវី ខៀវ សំផន សម្រាប់គោលបំណងនេះ (ប្រតិចារឹក, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣, ទំព័រ ១៨)។ អង្គជំនុំជម្រះយល់ស្របទៅនឹងសំណូមពរ និងឆន្ទៈនេះ និងផ្តល់ឲ្យមេធាវីការពារក្តី ខៀវ សំផន នូវរយៈពេលកន្លះថ្ងៃ នៅពេលបញ្ចប់សវនាការដេញដោលលើឯកសារសំខាន់ៗ ដើម្បីផ្តល់យោបល់លើឯកសារនានាដែលភាគីផ្សេងៗទៀតបានបង្ហាញនៅក្នុងសវនាការ ឬមិនដូច្នេះទេ បង្ហាញនូវចំណុចនានានៃកំណត់ហេតុឯកសារឯពេលសវនាការ ផ្តើមចេញពីទស្សនៈរបស់ជនជាប់ចោទ ខៀវ សំផន។ ប្រសិនបើក្រុមមេធាវីការពារក្តី ខៀវ សំផន មិនប្រើប្រាស់ឱកាសនេះទេ អង្គជំនុំជម្រះមានសិទ្ធិបដិសេធសំណើបន្ថែមរបស់មេធាវីការពារក្តី ខៀវ សំផន ក្នុងការបន្ថែមថិរវេលា ឬចំនួនទំព័រដែលបានកំណត់លើសពីពេលវេលា និងចំនួនទំព័រដែលបានអនុញ្ញាត សម្រាប់ការធ្វើសារណាបញ្ចប់ និងសេចក្តីសន្និដ្ឋានបញ្ចប់នោះទេ។

៧. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងផ្តល់ការបែងចែកពេលវេលាដូចខាងក្រោម សម្រាប់សវនាការដេញដោលលើឯកសារជាចុងក្រោយ នៅក្នុងសំណុំរឿង ០០២/០១៖

- *អំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវ៖* សហព្រះរាជអាជ្ញា (២ ថ្ងៃ) សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (១ថ្ងៃ) និងមេធាវីការពារក្តី នួន ជា (កន្លះថ្ងៃ)
- *តួនាទីរបស់ជនជាប់ចោទ៖* សហព្រះរាជអាជ្ញា (១ ថ្ងៃ) សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (កន្លះថ្ងៃ) និងមេធាវីការពារក្តី នួន ជា (កន្លះថ្ងៃ) និង
- *មេធាវីការពារក្តី ខៀវ សំផន (ឯកសារគ្រប់ប្រភេទទាំងអស់ដែលក្រុមមេធាវី ខៀវ សំផន ស្នើសុំជំទាស់ ឬធ្វើការអធិប្បាយ)៖* (កន្លះថ្ងៃ)

៨. បន្ទាប់ពីមានការគូសបញ្ជាក់ថា ជនជាប់ចោទមានបំណងឆ្លើយសំណួរនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះផ្តល់ពេលវេលាចំនួន ០៦ ថ្ងៃពេញ សម្រាប់ការសួរសំណួរទៅជនជាប់ចោទម្នាក់ៗ (ឯកសារ E288/1) និងផ្តល់ពេលវេលាចំនួន ០២ ថ្ងៃ ទៅសហមេធាវីនាំមុខ សម្រាប់ជនជាប់ចោទម្នាក់ៗ (ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២០-២១, និង២៦)។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នាពេលបច្ចុប្បន្ន អង្គជំនុំជម្រះពុំទាន់ដឹងច្បាស់អំពីរយៈពេលដែលជនជាប់ចោទនឹងមានសមត្ថភាព ឬឆន្ទៈដើម្បីឆ្លើយសំណួររបស់អង្គជំនុំជម្រះ និងភាគីនៅឡើយ។ អង្គជំនុំជម្រះពុំទាន់បានគូសបញ្ជាក់អំពីពេលវេលាកំណត់សម្រាប់ការសួរសំណួរនេះ ដែលនឹងត្រូវអនុញ្ញាតឲ្យបន្ត ដរាបណាជនជាប់ចោទនៅមានឆន្ទៈដើម្បីឆ្លើយសំណួរ និងល្អិតល្អន់ការសួរសំណួរពីសំណាក់ភាគី នៅតែពាក់ព័ន្ធទៅនឹងអង្គហេតុក្រោមការពិភាក្សានៅក្នុងសំណុំរឿង ០០២/០១។ ភាគីនឹងទទួលដំណឹងនាពេលឆាប់ៗតាមដែលអាចធ្វើទៅបានអំពីកាលបរិច្ឆេទ

នៃការសួរសំណួរទៅជនជាប់ចោទ។ ក្នុងចំណោមកត្តាផ្សេងៗ ចំណុចនេះនឹងអាស្រ័យលើវត្តមានរបស់សាក្សីដែលនៅសេសសល់ ប្រសិនបើមាន។

៩. នៅឯកិច្ចប្រជុំរៀបចំសវនាការ មេធាវីការពារក្តី ខៀវ សំផន បានស្នើជាថ្មីសុំឱ្យមានការសម្រាកនៅក្នុងកិច្ចដំណើរការ មុនពេលសួរសំណួរទៅជនជាប់ចោទ ដើម្បីត្រៀមរៀបចំ (ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ទំព័រ ២៦-២៧)។ សំណើនេះត្រូវបានជំទាស់ដោយសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើនេះ ដោយហេតុថា កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ ខៀវ សំផន នៅក្នុងសំណុំរឿង០០២ បានដំណើរការអស់ពេលវេលាជាង ៤ ឆ្នាំ និងការជំនុំជម្រះអស់រយៈពេលចំនួន ១៨ ខែ ដោយធានាបាននូវពេលវេលាច្រើនមកហើយ សម្រាប់ជនជាប់ចោទ និងមេធាវីការពារក្តីរបស់គាត់ ឱ្យបានដឹងពេញលេញអំពីលក្ខណៈនៃការចោទប្រកាន់ប្រឆាំងនឹងគាត់។

១០. យ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំពន្យារពេលវេលាផុតកំណត់នៃការដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល សម្រាប់ភាគីទាំងអស់ រហូតដល់ ០៦ សប្តាហ៍ក្រោយពេលបញ្ចប់កិច្ចដំណើរការនីតិវិធីលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ (ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២១)។ បើទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះពុំអាចពន្យារពេលបន្ថែមទៀតឡើយ ហើយបានគូសបញ្ជាក់ថា ចំនួនទំព័រកំណត់សម្រាប់សារណាទាំងនេះ ដែលបានជូនដំណឹងដល់ភាគីរួចហើយ នឹងនៅរក្សាដដែល (ឯកសារ E163/5/4)។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ចំនួនទំព័រកំណត់ទាំងនេះ ពុំរាប់បញ្ចូលកំណត់សម្គាល់ចុងទំព័រឡើយ ប្រសិនបើកំណត់សម្គាល់ចុងទំព័រដែលភាគីបានផ្តល់សម្រាប់សារណាបញ្ចប់ការពិភាក្សាដេញដោលនោះ មានតែឯកសារយោងទៅលើភស្តុតាងឯកសារ ឬភស្តុតាងផ្សេងៗនៅចំពោះមុខអង្គជំនុំជម្រះ ប៉ុណ្ណោះ។ ថ្វីបើអង្គជំនុំជម្រះបានអនុញ្ញាតជាពិសេសឱ្យភាគីដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគីតែមួយភាសាផ្លូវការនៅ អ.វ.ត.ក ក៏ដោយ ភាគីត្រូវចាត់វិធានការដើម្បីធានាបានការបកប្រែទាន់ពេលវេលាតាមដែលអាចធ្វើទៅបាន នូវសារណាបញ្ចប់ការពិភាក្សាដេញដោល និងកំណត់សម្គាល់ចុងទំព័ររបស់ខ្លួន។

១១. នៅឯកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះបានគូសបញ្ជាក់ទៀតថា អង្គជំនុំជម្រះពិចារណាឃើញថា ក្រមព្រហ្មទណ្ឌកម្ពុជាគ្រប់ផ្នែកទាំងអស់ បច្ចុប្បន្ននេះ បានចូលជាធរមានហើយ និងថ្វីត្បិតភាគីបានដាក់សារណាស្តីពីច្បាប់ជាធរមានហើយក៏ដោយ ក៏ភាគីទាំងអស់អាចលើកអំពីបញ្ហានេះនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួនផងដែរ ប្រសិនបើមានបំណងធ្វើដូច្នេះ។

១២. អង្គជំនុំជម្រះសាលាដំបូងសូមផ្តល់សេចក្តីលម្អិតដូចខាងក្រោម ពាក់ព័ន្ធនឹងទម្រង់នៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល នៅក្នុងសំណុំរឿង ០០២/០១ ដែលនឹងប្រព្រឹត្តទៅប្រមាណ ៣០ ថ្ងៃ ក្រោយពេលដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល។

- សហព្រះរាជអាជ្ញា៖ ៣ ថ្ងៃ
- សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ ១ ថ្ងៃ
- ក្រុមមេធាវីការពារក្តី នួន ជា៖ ២ ថ្ងៃ
- ក្រុមមេធាវីការពារក្តី ខៀវ សំផន៖ ២ ថ្ងៃ

នៅពេលបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគី សហព្រះរាជអាជ្ញានឹងមានពេលវេលាចំនួន ០,៧៥ ថ្ងៃ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងមានពេលវេលាចំនួន ០,២៥ ថ្ងៃ ជាបន្តបន្ទាប់ សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបដិសេធ។ ជាចុងក្រោយ អង្គជំនុំជម្រះនឹងផ្តល់ពេលវេលាទៅក្រុមមេធាវីការពារក្តី និង/ឬ ជនជាប់ចោទ ដើម្បីធ្វើសេចក្តីសន្និដ្ឋានស្ថាពរ។

១៣.នេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងឯកសារ E263 និងឯកសារ E288/1។